**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 20-Nov-2014, 09:37
CMS/CFO: Sann Rada

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៤

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង: **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើតាមវិធាន៨៧ របស់ នួន ជា ទាក់ទងនឹងសោតទស្សន៍(រូបភាព) ដែលបានថតសម័យប្រជុំក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិនាថ្ងៃទី ១១ ខែ មករា ឆ្នាំ ១៩៧៩**

---

**<u>ដាក់ដោយ:</u>**

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ
Victor KOPPE
ព្រំ ផល្លា
សួន វិសាល
លីវ សុវណ្ណា
Doreen CHEN
Joshua ROSENSWEIG
Xiaoyang NIE

**<u>ចម្លងជូន:</u>**

**សហមេធាវី ខៀវ សំផន**

គង់ សំអុន
Arthur VERCKEN
Anta GUISSÉ

**សហព្រះរាជអាជ្ញា:**

ជា លាង
Nicholas KOUMJIAN

**<u>សហមេធាវី តំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ
Marie GUIRAUD

1. អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក សហមេធាវីការពារក្តី នួន ជា ("ក្រុមមេធាវីការពារក្តី") ដាក់សំណើនេះ ("សំណើ") សុំដាក់នៅក្នុងសំណុំរឿងនូវសោតទស្សន៍ (រូបភាព) ដែលបានថតនៅសម័យប្រជុំក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិនាថ្ងៃទី ១១ មករា ឆ្នាំ១៩៧៩ ("ភាពយន្តរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ")[1]។

2. ភាពយន្តរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ មានរូបភាពឯកសារនៃសម័យប្រជុំក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិនាថ្ងៃទី ១១ ខែ មករា ឆ្នាំ ១៩៧៩ ដែលលើកឡើងនៅក្នុងទូរលេខរបស់កម្ពុជាប្រជាធិបតេយ្យ ទាក់ទងនឹងការឈ្លានពានរបស់វៀតណាមមកលើកម្ពុជាប្រជាធិបតេយ្យ។ កិច្ចប្រជុំនេះមានសុន្ទរកថាជាច្រើន ពីបណ្តាអ្នកការទូតច្រើនរូប ទាក់ទងនឹងប្រធានបទនេះ រួមទាំងសុន្ទរកថារបស់អតីតព្រះមហាក្សត្រព្រះបាទនរោត្តម សីហនុ ដែលជាតំណាងកម្ពុជាប្រជាធិបតេយ្យ និងតំណាងសាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋសង្គមនិយមវៀតណាម និងបណ្តាលអ្នកការទូតផ្សេងទៀត។

3. ភាពយន្តរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ មានសម្រង់នៃកិច្ចប្រជុំថ្ងៃទី ១១ ខែ មករា ឆ្នាំ១៩៧៩។ ដោយការចំណាយខ្ពស់ក្នុងការថែរក្សា បណ្ណាល័យសោតទស្សន៍របស់អង្គការប្រជាជាតិបានផ្តល់យោបល់ថា ភាពយន្តនេះមានរូបភាពពេញលេញនៃកិច្ចប្រជុំនៅក្នុងបណ្ណាសារ ហើយថា ការអនុវត្តសម្រាប់ការផ្តិតយករូបភាព គឺផ្តិតយកតែរូបភាពសំខាន់ៗពីកិច្ចប្រជុំប៉ុណ្ណោះ ដើម្បីស្របតាមការអនុវត្តរបស់ក្រុមប្រឹក្សាសន្តិសុខនៅពេលនោះ។ ភាពយន្តរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ផ្តោតទៅលើសុន្ទរកថារបស់អតីតព្រះមហាក្សត្រព្រះបាទនរោត្តម សីហនុ និងការឆ្លើយតបពីឯកអគ្គរដ្ឋទូតចិន Chen Chu និងឯកអគ្គរដ្ឋទូតវៀតណាម Ha Van Lau ។

4. ក្រុមមេធាវីការពារក្តី បានស្នើសុំឱ្យទទួលយកដាក់ក្នុងបញ្ជីឯកសារបឋមរបស់ខ្លួនសម្រាប់សំណុំរឿង០០២/០២[2] ដែលដាក់នៅថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៤ នូវកំណត់ហេតុពេញលេញនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ។ ក្រុមមេធាវីការពារក្តីបានចង្អុលបង្ហាញ

---

[1] អាចរកបាននៅក្នុងឃ្លាំងផ្ទុកឯកសាររួមនៅ ERN V01034071។

[2] ឯកសារលេខ E-307/5 "បញ្ជីរឯកសារបឋមសំរាប់ករណី០០២/០២" ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៤។

នៅក្នុងសំណើនោះថា កំណត់ហេតុនៃកិច្ចប្រជុំនេះនឹងមានទម្រង់ជាលាយលក្ខណ៍អក្សរ និងជារូបភាព។

5. ភាពយន្តរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិទាក់ទងនឹងបញ្ហាដែលជាចំណុចស្នូលដល់ការការពារក្តី នួន ជា។ សំណើនេះបំពេញបានតាមការវាយតម្លៃក្រោមលក្ខខណ្ឌប្រាំ (five-factored test) ដែលបានចែងនៅក្នុងវិធាន៨៧(៣) និងដាក់បញ្ចូលវិធាន៨៧(៤) សម្រាប់ការទទួលយកឯកសារថ្មីក្នុងសំណុំរឿង។ ទាក់ទងនឹងចំណុចនេះក្រុមមេធាវីការពារក្តីកត់សំគាល់យ៉ាងច្បាស់ថា ខណៈដែលកំណត់ហេតុជាលាយលក្ខណ៍នៃកិច្ចប្រជុំនេះទាក់ទងនឹងប្រធានបទដូចគ្នានឹងភាពយន្តរបស់ក្រុមប្រឹក្សាសន្តិសុខ សំណើនេះមិនអាចចាត់ទុកថា មិនពាក់ព័ន្ធ ច្រំដែល ឬក៏ មិនសំខាន់នោះទេ ដោយសារភាពយន្តរបស់ក្រុមប្រឹក្សាសន្តិសុខ និងកំណត់ហេតុដែលពាក់ព័ន្ធមានទម្រង់ខុសគ្នា។ តែភាពយន្តរបស់ក្រុមប្រឹក្សាសន្តិសុខ គឺជារូបភាពកម្រឃើញនៃព្រឹត្តិការណ៍ជាក់លាក់នៅក្នុងប្រវត្តិសាស្ត្រកម្ពុជា។ ក្រុមមេធាវីការពារក្តីមានបំណងបង្ហាញនៅតុលាការនូវភាពយន្តរបស់ក្រុមប្រឹក្សាសន្តិសុខដល់ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងក្នុងអំឡុងពេលជំនុំជម្រះក្នុងសំណុំរឿង០០២/០២ ដែលអាចមានប្រយោជន៍ដល់សាធារណជនផងដែរ។

6. ក្រុមមេធាវីការពារក្តីទទួលស្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានសម្រេចរួចមកហើយថា ដើម្បីឱ្យឯកសារត្រូវបានទទួលយកជាភស្តុតាងស្របតាមវិធាន៨៧(៤) ភាគីត្រូវតែបង្ហាញឱ្យសមហេតុផលថា ភស្តុតាង "ពុំមានឡើយនៅមុនការបើកការជំនុំជម្រះ ឬភស្តុតាងទាំងនោះពុំទាន់រកឃើញឡើយ បើទោះជាខ្លួនខិតខំព្យាយាមយ៉ាងណាក្តី"[3]។ ទាក់ទងនឹងចំណុចនេះក្រុមមេធាវីការពារក្តីអះអាងចំពោះមុខអង្គជំនុំជម្រះសាលាដំបូងថា ខ្លួនបានខិតខំព្យាយាមឱ្យអស់ពីសមត្ថភាពដើម្បីទទួលបានភាពយន្តនេះឱ្យបានឆាប់បំផុត តាមតែអាចធ្វើបាន។ សេចក្តីលំអិតនៃការខិតខំព្យាយាមរបស់ក្រុមមេធាវីការពារក្តីដើម្បីទទួលបានភាពយន្តរបស់ក្រុមប្រឹក្សាសន្តិសុខ មានដូចខាងក្រោម:

ក. ក្រុមមេធាវីការពារក្តីបានដឹងពីអត្ថិភាពនៃភាពយន្តរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិនៅខែ មិថុនា ឆ្នាំ ២០១៤។ ក្រោយពីបានកំណត់ថា បណ្ណាល័យរបស់ អ.វ.ត.ក មានបំណងបញ្ជាទិញភាពយន្តនេះ ក្រុមមេធាវីការពារក្តីចាប់ផ្តើម

---

[3] ឯកសារលេខ E-276/2 "ចម្លើយតបទៅនឹងសំណើតាមវិធាន៨៧(៤) របស់សហព្រះរាជអាជ្ញា នួន ជា និង ខៀវ សំផន" ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ នៅកថាខណ្ឌ ៣។

ដាក់បញ្ជាទិញភាពយន្តនេះនៅដើមខែ កក្កដា ឆ្នាំ ២០១៤ ដែលជាឱកាសដំបូងបំផុត ដោយសារបណ្ណាល័យ អ.វ.ត.ក យល់ព្រមលើការបញ្ជាទិញសម្ភារៈថ្មីតែពីរដងក្នុងរយៈពេលមួយឆ្នាំ (ជារៀងរាល់ខែ មករា និងខែ កក្កដា)។

ខ. ភាពយន្តរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ជាភាពយន្តមានទំហំ ១៦ មីលីម៉ែត្រ ហើយអាចបញ្ជូនមកបានតែក្រោយពីវាត្រូវគេផ្លាស់ប្តូរទំរង់ ដោយអ្នកផ្គត់ផ្គង់ខាងក្រៅមួយដោយយកប្រាក់កម្រៃ ដែលត្រូវចំណាយដោយ អ.វ.ត.ក ។ ដោយសារ អ.វ.ត.ក កង្វះខាតខាងថវិកា ភាពយន្តត្រូវបានបញ្ជាទិញក្នុងតំលៃទាបបំផុត ហើយពេលវេលានៃការបញ្ជូនអាចមានរយៈពេលយូរ។

គ. មានការពន្យារពេលបន្ថែមនៅក្នុងការបញ្ជូនភាពយន្តនេះ ដោយសារការពិភាក្សាទូទៅរបស់មហាសន្និបាតអង្គការសហប្រជាជាតិនៅចុងខែ កញ្ញា ឆ្នាំ ២០១៤ រំខានដល់ការប្រព្រឹត្តទៅរបស់បណ្ណាសារដ្ឋានរបស់អង្គការសហប្រជាជាតិ។ ទីបំផុតភាពយន្តរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ត្រូវបានប្រគល់ដល់ក្រុមមេធាវីការពារក្តីនៅថ្ងៃទី ៧ ខែ តុលា ឆ្នាំ ២០១៤។

ឃ. ជាបន្ទាប់មកក្រុមមេធាវីការពារក្តីស្វះស្វែងភ្ជាប់ភាពយន្តរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ជាសម្ភារៈបន្ថែមទៅលើកំណត់ហេតុនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ដែលបានដាក់នៅក្នុងសំណុំរឿងរួចហើយ ប៉ុន្តែក្រុមមេធាវីការពារក្តីបានដឹងនៅថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៤ ថា អង្គជំនុំជម្រះសាលាដំបូងតម្រូវថា សម្ភារៈដែលស្នើសុំដាក់ក្នុងសំណុំរឿង ត្រូវតែធ្វើឡើយតាមសំណើផ្លូវការ។

ង. នៅថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤ នួន ជា ណែនាំក្រុមមេធាវីការពារក្តីមិនឲ្យចូលរួមដំណើរការនីតិវិធីនៅក្នុងករណី០០២/០២ រហូតដល់មានសេចក្តីសម្រេចលើបណ្តឹងជិតចិត្ត របស់គាត់ដកចៅក្រមបួនរូប។ ដោយសារសេចក្តីសម្រេចនោះត្រូវបានជូនដំណឹងមកក្រុមមេធាវីការពារក្តី (ដោយគ្មានសម្អាងហេតុ) នៅវេលាម៉ោង

៤:១៤ រសៀលថ្ងៃសុក្រទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤[4] ក្រុមមេធាវីការពារក្ដីសូមដាក់សំណើនេះនៅពេលនេះ។

7. អាស្រ័យហេតុនេះ មេធាវីការពារក្ដីសូមស្នើដាក់ភាពយន្តរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិនេះ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងសុំឲ្យទទួលយកជាភស្តុតាង។

សហមេធាវីការពារក្ដីលោក នួន ជា

**សុន អរុណ** **Victor KOPPE**

[4] ឯកសារលេខ E314/12 "សេចក្ដីសម្រេចលើបណ្ដឹងជំទាស់ជំនុំជម្រះ" ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤។